# ការសិក្សាអំពីចិនតាមទស្សនៈថ្មី (A New Sinology)

**ដោយ លោក ខេវិន រ៉ាត់** (Kevin Rudd) **នាយករដ្ឋមន្ត្រីប្រទេសអូស្ត្រាលី**

អំណាច និងឥទ្ធិពលរបស់ប្រទេសចិនកំពុងតែរីកធំធាត់។ ប៉ុន្តែអនាគតរបស់ប្រទេសនេះនៅតែស្រពិចស្រពិល។ ដើម្បីស្វែងយល់ថាតើចិននឹងដើរតួនាទីអ្វី នៅក្នុងការរៀបចំសណ្តាប់ធ្នាប់ពិភពលោក យើងត្រូវតែស្វែងយល់អំពីប្រទេសនេះអោយបានជ្រាលជ្រៅជាងមុន និងបង្កើនទំនាក់ទំនងដោយស្មោះត្រង់ជាមួយចិនអោយបានច្រើនជាងមុន។

ប្រទេសអូស្ត្រាលីមានអ្នកគិតគូរ និងអ្នកនិពន្ធអំពីប្រទេសចិនជាយូរលង់ណាស់មកហើយ ដូចជា លោក ចច អ៊ី ម៉ូរីសាន់ (George E. Morrison) ដែលបំរើការជាអ្នកយកការទីមួយនៅប្រទេសចិនអោយកាសែត *ដឹ ថាម* (The Times)។ អ្នកគិតគូរទាំងនោះតែងតែដឹងច្បាស់ថាចំណេះដឹងអំពីប្រទេសចិនត្រូវតែឈរលើមូលដ្ឋាននៃការស្វែងយល់អំពី ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងទស្សនៈវិជ្ជាកាលពីអតីតកាលរបស់ចិន។ វាគឺជាទំលាប់ដែលមានការអធ្យាស្រ័យល្អ ប៉ុន្តែប្រកបដោយការវិភាគយ៉ាងច្បាស់លាស់។

ដើម្បីវិភាគអំពីអនាគតរបស់ប្រទេសចិន យើងត្រូវតែស្វែងយល់អោយបានច្បាស់លាស់អំពីវប្បធម៌ដ៏វិសេសវិសាលរបស់ចិន រួមមានការវិវត្តដ៏យូរលង់ណាស់មកហើយនៃកំណែទំរង់ និងទំនាក់ទំនងជាមួយបរទេស។ នេះគឺជាកិច្ចការស្មុគស្មាញ។ នៅក្នុងប្រទេសចិនផ្ទាល់ មានទស្សនៈផ្សេងៗដែលមិនចុះសំរុងនឹងគ្នាជាច្រើនអំពីប្រវត្តិសាស្ត្រ បច្ចុប្បន្នកាល និងអនាគតកាលរបស់ប្រទេសមួយនេះ។

នេះជាហេតុផលដែលយើងបង្កើត មជ្ឈមណ្ឌលអូស្ត្រាលីអំពីប្រទេសចិននៅក្នុងពិភពលោកនេះឡើង ដែលស្ថិតនៅក្នុងសាកលវិទ្យាល័យជាតិអូស្ត្រាលី។ មជ្ឈមណ្ឌលនេះនឹងក្លាយជាវិទ្យាស្ថានអន្តរជាតិមួយដែលនឹងពង្រីកការយល់ដឹងអំពីប្រទេសចិន ព្រមទាំងជំរុញឱ្យមានកិច្ចសន្ទនាជាមួយប្រទេសចិន។ ជាងនេះទៅទៀត វានឹងផ្តោតការយកចិត្តទុកដាក់ទៅលើតួនាទីរបស់ចិននៅក្នុងពិភពលោក។

មជ្ឈមណ្ឌលនេះនឹងត្រូវបានបង្កើតឡើង ស្របពេលដែលមានការប្រែប្រួលដ៏គួរឱ្យកត់សំគាល់នៅក្នុងប្រទេសចិន ដែលធ្វើឱ្យមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ថាតើប្រទេសចិនមើលឃើញអំពីតួនាទីរបស់ខ្លួនអ្វីខ្លះនាពេលអនាគត។ មានទស្សនៈជ្រុលនិយមខ្លះ បានចាត់ទុកថាការរីកចំរើនរបស់ចិនគឺជាការគំរាមកំហែងមួយដល់សណ្តាប់ធ្នាប់របស់ពិភពលោក។ មានទស្សនៈផ្ទុយមួយយល់ឃើញថា ‘កុងសង់ស៊ីសប៉េកាំង’ (Beijing consensus) ត្រូវតែជំនួសអោយ ‘កុងសង់ស៊ីសវ៉ាស៊ីនតោន’ (Washington consensus)។ ហើយមានទស្សនៈជាច្រើនទៀតនៅចន្លោះកុងសង់ស៊ីសទាំងពីរ។ ឯការពិតនោះគឺមានទស្សនៈមិនចុះសំរុងនឹងគ្នាជាច្រើនអំពីចិននិងអនាគតរបស់គេ ហើយទស្សនៈមិនចុះសំរុងនឹងគ្នានេះមានទាំងនៅក្នុងស្រទាប់ជនជាតិចិន ក៏ដូចជាបរទេស។

ប្រទេសចិនបានទទួលប្រយោជន៍យ៉ាងច្រើនអំពីគោលនយោបាយកំណែទំរង់សេដ្ឋកិច្ចក្នុងស្រុក និងទំនាក់ទំនងសេដ្ឋកិច្ចជាមួយពិភពលោក។ ប៉ុន្តែមានការជជែកដេញដោលនៅឡើយអំពីកំណែទំរង់នេះ។ ហើយក៏មានការជជែកអំពីអនាគតរបស់ប្រទេសចិនជាលក្ខណៈអន្តរជាតិផងដែរ។ មានចំណោទមួយចំនួនអំពីបញ្ហាសិទ្ធមនុស្ស និងការអភិវឌ្ឍន៍នូវប្រព័ន្ធច្បាប់មួយដែលឯករាជ្យនិងមានតម្លាភាពពិតប្រាកដ នៅប្រទេសចិន។ ហើយមិត្តភក្តិរបស់ប្រទេសចិនក៏ចង់ឃើញប្រព័ន្ធសេដ្ឋកិច្ចរបស់ចិនត្រូវបានអភិវឌ្ឍ តាមលំនាំដែលដឹកនាំប្រទេសនិងប្រជាជនចិនអោយចូលរួមយ៉ាងពេញលេញទៅក្នុងសេដ្ឋកិច្ចពិភពលោក។

ប្រទេសចិនដែលកាន់តែរីកចំរើននេះនឹងបន្តកិច្ចការរបស់ខ្លួននៅក្នុងពិភពលោក នេះជាការធម្មតា។ ហើយខ្ញុំជឿថាប្រទេសចិននឹងទទួលស្គាល់ថា ផលប្រយោជន៍ជាមូលដ្ឋានរបស់ខ្លួននឹងស្ថិតនៅជាមួយ មានន័យថាមិនប្រឆាំង នឹងប្រព័ន្ធអន្តរជាតិ ដែលបំរើអោយប្រទេសចិនយ៉ាងប្រពៃកន្លងមកនោះទេ។ យើងបានសង្កេតឃើញលក្ខខ័ណ្ឌនេះ កើតមានរួចមកហើយនៅក្នុងតួនាទីរបស់ប្រទេសចិនក្នុងចំណោមក្រុមប្រទេស G 20 ដែលចិនបានធ្វើជាដៃគូជាមួយប្រទេសសេដ្ឋកិច្ចធំៗ ដើម្បីដោះស្រាយវិបត្តិសេដ្ឋកិច្ចពិភពលោក។ ប្រទេសចិនក៏កំពុងធ្វើការជាមួយនឹងសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ហើយចិនត្រូវតែឈានមុខគេជាងមុននៅក្នុងបញ្ហាដ៏ស្រួចស្រាវមួយនេះ។

ប្រទេសចិន ក៏មានទំនាក់ទំនងយ៉ាងសកម្មជាមួយប្រទេសដ៏ទៃទៀតនៅតំបន់អាស៊ីប៉ាស៊ីភិច និងរួមចំណែកជាមួយគោលដៅរបស់អូស្រ្តាលី ដើម្បីកសាងស្ថាបត្យកម្មថ្នាក់តំបន់មួយដែលសមស្របសំរាប់ដោះស្រាយបញ្ហាប្រឈមនានាក្នុងពេលអនាគត។

វិភាគទានរបស់ប្រទេសចិននៅក្នុងការរៀបចំសណ្តាប់ធ្នាប់ពិភពលោក គឺមានមិនអាចប្រកែកបាន។ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ។ ចិនអាច និងគួរតែធ្វើកិច្ចការអោយបានច្រើនជាងមុនដើម្បីជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អន្តរជាតិ ក្នុងការប្រឈមនឹងបញ្ហាសន្តិសុខពិភពលោកដូចជា បញ្ហាប្រទេសអាហ្គានីស្ថាន និងអ៊ីរ៉ង់។

ការចូលរួមរបស់ប្រទេសចិនជាតួអង្គសំខាន់មួយនៅក្នុងការរក្សា និងពង្រឹងសណ្តាប់ធ្នាប់ដែលមានស្ថេរភាពនិងមានច្បាប់ទំលាប់ គឺជាកិច្ចការមួយដែលល្អសំរាប់ប្រទេសចិន ក៏ដូចជាពិភពលោកទាំងមូល។

ដើម្បីស្វែងយល់ថាតើចិន នឹង អាច និងគួរតែ ដើរតួអ្វីនៅក្នុងការរៀបចំសណ្តាប់ធ្នាប់ពិភពលោកនោះ យើងត្រូវតែស្វែងយល់អំពីចិនអោយបានជ្រៅជ្រះជាងមុន និងបង្កើនទំនាក់ទំនងដោយស្មោះត្រង់ជាមួយចិន អោយបានច្រើនជាងមុននៅគ្រប់កំរិត។ ខ្ញុំជឿថាពួកយើងដល់ពេលដែលត្រូវចាប់ផ្តើមនូវការសិក្សាអំពីចិនតាមទស្សនៈថ្មីហើយ (A New Sinology)។

ការងារនេះត្រូវតែបើកទូលាយអោយធំជាងទស្សនៈកាលពីសម័យសង្រ្គាមត្រជាក់ 'fan-Hua or qin-Hua' ដែលមានន័យថា ប្រឆាំងនឹងចិន ឬបក្សពួកចិន។ ការពិតជាក់ស្តែងគឺវាសាំញ៉ាំជាងប្រយោគបដិបក្សមួយនេះ។ យើងគួរតែអាចសំដែងទៅកាន់ប្រទេសចិននូវទស្សនៈរបស់យើងដោយផ្អែកលើគោលតំលៃ និងជំនឿរបស់យើងដោយមិនចាំបាច់ប៉ះពាល់ដល់ចំណងមិត្តភាពជាមួយចិន ឬក៏ចំណងមិត្តភាពចិនជាមួយអូស្រ្តាលី។ យើងត្រូវការកិច្ចសន្ទនាមួយដែលជឿនលឿនជាងមុន ជាផ្លូវឆ្ពោះទៅមុខសំរាប់អំណាចដែលកាន់តែរីកធំធាត់មួយនេះ។

ខ្ញុំចង់ឃើញកិច្ចសន្ទនានេះឈរលើគោលការ zhengyou។ Zhengyou ជាមិត្តល្អ ជាដៃគូដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន និងជាអ្នកដែលនិយាយការពិត ដែលជាស្នូលនៃចំណងមិត្តភាពដោយស្មោះត្រង់ និងស៊ីជំរៅ។

នៅក្នុងករណីអូស្រ្តាលី នេះមានន័យថាយើងអាចនិយាយជាមួយចិនដោយស្មោះត្រង់នៅក្នុងកិច្ចការណាដែលមានផលប្រយោជន៍របស់យើងពាក់ព័ន្ធ និងសង្ឃឹមថាចិនក៏ធ្វើដូចគ្នា ពោលគឺ

ជាកិច្ចសន្ទនាដែលមានការគោរព ការយល់អធ្យាស្រ័យ និងការទទួលស្គាល់នូវតំលៃរបស់ភាគីម្ខាងទៀតទៅវិញទៅមក។ គោលការណ៍ថ្មីនៃទំនាក់ទំនង និងការយល់អធ្យាស្រ័យនេះមានសារៈសំខាន់ណាស់សំរាប់ប្រទេសចិន ក៏ដូចជាអូស្ត្រាលី និងសមូហភាពលោកខាងលិចដែរ។

*នេះជាការដកស្រង់បាឋកថាចច អ៊ី ម៉ូរីសានលើកទី70 ដែលថ្លែងដោយនាយករដ្ឋមន្ត្រីអូស្ត្រាលីឯកឧត្តម ខេវិន រ៉ាត់ នៅឯពិធីសម្ពោធមជ្ឈមណ្ឌលអូស្ត្រាលីអំពីប្រទេសចិននៅលើពិភពលោក*